អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍
# របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង 004

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លោក យឹម ទិត្យ ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍ខ្មែរក្រោម
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ "ប្រជាជន ១៧ មេសា" "អ្នកជម្លៀសមកពីភូមិភាគបូព៌ា" និងកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ ការធ្វើទុក្ខបុកម្នេញមកលើខ្មែរក្រោម និងជនជាតិវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ
- អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា និងការនិរទេស ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ក្នុងនោះរួមមាន មនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទថាបានប្រព្រឹត្តផ្សេងៗគ្នានៅខេត្តតាកែវ (ភូមិភាគនិរតី)នៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រេល ទីតាំងសម្លាប់មនុស្សវត្តអង្គណទីតាំសម្លាប់មនុស្សព្រៃភូមិស្លែងទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) នៅមន្ទីរសន្តិសុខគាស់ក្រឡ អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធសហករណ៍ធិបតី រួមមានមន្ទីរសន្តិសុខវត្ត ធិបតី និងមន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស ការដ្ឋានទំនប់កង្កួតមន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករកំពង់គុល ការដ្ឋានភ្នំត្រដាក់ចិត្ត ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រី ស្រុកសំឡូត មន្ទីរសន្តិសុខវត្តធម្មយុត មន្ទីរសន្តិសុខវត្តសម្តេច ឃុំកំពង់ព្រៀង រួមមានភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ឃុំរាំងកេសី រួមមាន វត្តរាំងកេសី

និងភូមិរាំងកេសី មន្ទីរសន្តិសុខវត្តគិរីរម្យ និងមន្ទីរសន្តិសុខវត្តកណ្តាល ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)នៅមន្ទីរសន្តិសុខភ្នំវាល មន្ទីរសន្តិសុខស្វាយជ្រំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី គុកលេខ ៨ និងទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តបន្ទាយមានជ័យ (ភូមិភាគពាយ័ព្យ) នៅមន្ទីរសន្តិសុខវត្តបន្ទាយនាង មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ការដ្ឋានស្ពានស្រែង និងទំនប់ព្រៃរនាម វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ និងការដ្ឋានទំនប់ត្រពាំងថ្ម។

ឥឡូវនេះ តាមរយៈមេធាវីរបស់គាត់ លោក យឹម ទិត្យ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ហើយអាចចូលរួមកិច្ចស៊ើបសួរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh